# ធនាគារជាតិនៃកម្ពុជា



# របាយការណ៍ប្រចាំឆ្នាំ ២០១០

អគ្គនាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



បន្ទាប់ពីការទទួលរងនូវសំពាធនៃវិបត្តិជាសកលនាអំឡុងពីរឆ្នាំចុងក្រោយនេះ កិច្ចខិតខំប្រឹងប្រែងរួមគ្នាត្រូវបានរៀបចំដើម្បីស្តារឡើងវិញនូវការខូចខាត។ នៅក្នុងប្រទេសកម្ពុជា សញ្ញានៃការងើបឡើងវិញបានបង្ហាញឲ្យឃើញនៅក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០។ ការងើបឡើងវិញនេះបណ្តាលមកពីការរីកចម្រើននៅក្នុងវិស័យសេដ្ឋកិច្ចចម្បងដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និង សេវាកម្ម។ វិស័យធនាគារក៏បានចូលរួមយ៉ាងសកម្មនៅក្នុងការរួមចំណែកឲ្យមានកំណើនសេដ្ឋកិច្ចផងដែរ ។

វិបត្តិសេដ្ឋកិច្ច សកលបានជំរុញឲ្យមានតម្រូវការក្នុងការលើកកម្ពស់បទបញ្ញាប្រុងប្រយ័ត្នបន្ថែមទៀតដើម្បីឲ្យមានភាពសមស្របទៅនឹងបច្ចុប្បន្នភាពនៃប្រតិបត្តិការធនាគារ និងអាចរក្សាបានស្ថិរភាពហិរញ្ញវត្ថុ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឡើងវិញនូវក្របខណ្ឌនៃការត្រួតពិនិត្យ និងបទបញ្ញាប្រុងប្រយ័ត្នរបស់ខ្លួនដើម្បីទប់ទល់ជាមួយកត្តាប្រឈមនៃហានិភ័យសក្តានុពលមួយចំនួន ជាពិសេស តាមរយៈការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រតិបត្តិការធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ តួយ៉ាង ធនាគារជាតិនៃកម្ពុជា បានដាក់ចេញឲ្យអនុវត្តនូវបទបញ្ញាប្រុងប្រយ័ត្នសំខាន់ៗមួយចំនួនទៀតដូចជា ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុង និងប្រកាសស្តីពីការអនុវត្តការត្រួតពិនិត្យ លើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត។ បទប្បញ្ញត្តិថ្មីៗទាំងនេះ នឹងជួយជំរុញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងមូលមាន សុវត្ថិភាព និងភាពរឹងមាំបន្ថែមទៀត។

ក្រៅពីការពង្រឹងបទបញ្ញាប្រុងប្រយ័ត្ន ធនាគារជាតិនៃកម្ពុជា ក៏បានយកចិត្តទុកដាក់ក្នុងការពង្រឹងលទ្ធភាពទទួលយកសេវាកម្មហិរញ្ញវត្ថុតាមរយៈការជំរុញឲ្យគ្រឹះស្ថានធនាគារ ពង្រីកតំបន់ប្រតិបត្តិការ បើកលទ្ធភាពឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលយកប្រាក់បញ្ញើពីសាធារណៈជន និង អភិវឌ្ឍន៍ផលិតផលតាមបច្ចេកវិទ្យាទំនើប ក្នុងនោះដូចជា ការដាក់ឲ្យប្រើប្រាស់នូវសេវាកម្មធនាគារតាមអ៊ីនធឺណែត និងសេវាកម្មផ្ទេរប្រាក់ចល័តជាដើម។ ការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្របមួយ សម្រាប់អភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុក៏ជាកិច្ចការស្នូលរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា កំពុងខិតខំរៀបចំបង្កើតទីផ្សារអន្តរធនាគារ ការិយាល័យឥណទាន ព្រមទាំងពង្រឹងអភិបាលកិច្ចនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជា តែងយកចិត្តទុកដាក់ក្នុងការកសាងសមត្ថភាពមន្ត្រី បុគ្គលិកដើម្បីអនុវត្តនូវតួនាទីនិងភារកិច្ចប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ។ ការកសាងសមត្ថភាពនេះធ្វើឡើងក្នុងទិសដៅឲ្យមន្ត្រីបុគ្គលិកទាំងនោះទទួលបាននូវចំណេះដឹងថ្មីៗ សម្រាប់ឆ្លើយតបទៅតាមការរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា តំបន់ និងសកលលោក។ កិច្ចខិតខំប្រឹងប្រែងនេះក៏ត្រូវបានទទួលការជួយឧបត្ថម្ភគាំទ្រពីសំណាក់មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី មជ្ឈមណ្ឌលស៊ាសិន

រតនាគារអាមេរិក និងធនាគារកណ្តាលផ្សេងទៀត ជាដើម។ ជាមួយគ្នានេះ ក្របខ័ណ្ឌនៃវិស័យធនាគារ និងហិរញ្ញវត្ថុ មិនត្រឹមតែស្ថិតក្នុងបរិបទផ្ទៃក្នុងប្រទេសនោះទេ ប៉ុន្តែភាពទាក់ទងនៃវិស័យនេះកាន់តែមានភាពស្មុគស្មាញ និងជួបប្រទះនូវភាពប្រឈមជាមួយប្រតិបត្តិការជាអន្តរជាតិ។ ក្នុងន័យនេះ ធនគារជាតិនៃកម្ពុជាបានបង្កើតទំនាក់ទំនងយ៉ាងសកម្មជាមួយបណ្តាធនាគារកណ្តាលនៃ ប្រទេសជាច្រើន សំដៅធ្វើការចែករំលែកព័ត៌មានបទពិសោធន៍ និងចំណេះដឹងថ្មីៗ រវាងគ្នាទៅវិញទៅមក។

ប្រតិបត្តិការនៅក្នុងវិស័យធនាគារមានការរីកចម្រើនគួរឲ្យចាប់អារម្មណ៍នៅក្នុងឆ្នាំ២០១០ និង ប្រកបដោយសុទិដ្ឋិនិយមសម្រាប់ពេលអនាគត។ ឥណទាន និងប្រាក់បញ្ញើ របស់អន្តការីធនាគារមានការកើនឡើងយ៉ាងខ្លាំង។ រីឯ ទ្រព្យសកម្មសរុបនៅក្នុងវិស័យធនាគារកើនឡើងដល់ ៥៦% នៃផលិតផលក្នុងស្រុកសរុប ដែលនៅតែគ្របដណ្តប់នៅលើវិស័យហិរញ្ញវត្ថុទាំងមូល។ ដោយឡែក ឥណទានមិនដំណើរការស្ថិត ក្នុងកម្រិតទាបដែលក្នុងនោះ ការធ្វើសំវិធានធនមានកម្រិតគ្របដណ្តប់គ្រប់គ្រាន់។ ចំណែកឯឥណទានហានិភ័យធំ ឥណទានសម្ព័ន្ធញ្ញាតិ និងឥណទានតាមវិស័យសេដ្ឋកិច្ច បានបង្ហាញថាហានិភ័យឥណទាននៅ ក្នុងវិស័យធនាគារមានកម្រិតទាប។ ចំពោះសាច់ប្រាក់ងាយស្រួលមិនមានបញ្ហាគួរឲ្យចាប់អារម្មណ៍នោះទេ ដោយសារវិស័យធនាគារមានសាច់ប្រាក់ងាយស្រួលបម្រុងច្រើន ហើយមានការកើនឡើងជាលំដាប់។ ហានិភ័យទីផ្សារមានកម្រិតតិចតួចប៉ុណ្ណោះ ដោយសារទីផ្សារទុន និងទីផ្សាររូបិយវត្ថុមិនទាន់មានរូបរាងជា ដុំកំភួននៅឡើយ។ ការកើនឡើងនៃប្រតិបត្តិការ និងភាពចម្រុះនៃផលិតផលបានធ្វើឲ្យគ្រឹះស្ថានធនាគារ ប្រឈមនឹងហានិភ័យប្រតិបត្តិការខ្ពស់ជាងមុន ប៉ុន្តែស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបាន។

ជាមួយគ្នានេះ វិស័យមីក្រូហិរញ្ញវត្ថុនៅតែរក្សាតួនាទីចាំបាច់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជននៅតាមតំបន់ជនបទ។ ការរីកចម្រើនថ្មីៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ត្រូវបានមើលឃើញតាមរយៈការពង្រឹងសមត្ថភាពក្នុងការបង្កើនជំនឿទុកចិត្ត និង ពង្រីករចនាសម្ព័ន្ធប្រតិបត្តិការសម្រាប់ទទួលប្រាក់បញ្ញើពីសាធារណជន។ អត្រាកំណើននៃប្រាក់បញ្ញើ បានកើនឡើងលើសឥណទានប្រមាណ ៦ដង បើធៀបពីឆ្នាំ២០០៩ ទៅឆ្នាំ២០១០ តែទោះបីជាយ៉ាងណា កម្រិតនៃប្រាក់បញ្ញើពុំទាន់អាចឆ្លើយតបទៅតាមតម្រូវការនៃទំហំឥណទានបាននៅឡើយ។ គុណភាពឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានពង្រឹង ដែលធ្វើឲ្យអត្រាឥណទានមិនដំណើរការមានការថយចុះ។ ម្យ៉ាងវិញទៀត គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅពឹង ផ្អែកច្រើនទៅលើប្រភពទុនពីបរទេស ដែលជាកត្តានាំឲ្យមានការប្រឈមជាមួយហានិភ័យអត្រាប្តូរប្រាក់។ ដូច្នេះ ការប្រមូលប្រាក់បញ្ញើជារូបិយវត្ថុជាតិ នឹងអាចកាត់បន្ថយហានិភ័យអត្រាប្តូរប្រាក់ ហើយពិសេស ផ្តល់ជាប្រភពទុនយ៉ាងសំខាន់ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ជារួម ស្នាដៃសម្រេចបានក្នុងឆ្នាំ២០១០នេះ បាននាំមកនូវការរីកចម្រើននៃប្រព័ន្ធធនាគារ តាមរយៈវិសាលភាពនៃទំហំប្រតិបត្តិការ ការរក្សាភាពរឹងមាំនៃប្រព័ន្ធធនាគារក្នុងអំឡុងពេលវិបត្តិជាសកល និងជាពិសេសការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិជាដើម។ ទោះបីទទួលបានលទ្ធផលដូច្នេះ ប៉ុន្តែកត្តាប្រឈមជាច្រើនក៏បានចូលមកទន្ទឹមគ្នាផងដែរ ក្នុងនោះ ធនាគារជាតិនៃកម្ពុជា ជាពិសេសអគ្គនាយកដ្ឋានត្រួតពិនិត្យនឹងត្រូវដើរតួនាទីយ៉ាងសកម្មក្នុងការទប់ទល់ និងដោះស្រាយជាមួយកត្តាប្រឈមទាំងនោះ រួមមានដូចជា ការសិក្សាឲ្យបានច្បាស់លាស់ ក្នុងន័យធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិ ដើម្បីអាចឆ្លើយតបជាមួយការវិវឌ្ឍន៍រីកចម្រើនរបស់វិស័យ

ធនាគារនិងហិរញ្ញវត្ថុនៅក្នុងតំបន់ និងអន្តរជាតិ។ មិនតែប៉ុណ្ណោះ កត្តាសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យ ចាំបាច់ត្រូវទាមទារឲ្យមានការបណ្តុះបណ្តាល និងពង្រឹងជាប្រចាំ ជាពិសេស ការស្វែងយល់ពីវិធីសាស្ត្រត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏ជំរុញឲ្យមានការសហការណ៍យ៉ាងសកម្ម រវាងអាជ្ញាធរត្រួតពិនិត្យជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងន័យអនុវត្តឲ្យមានប្រសិទ្ធភាពនូវវិធីសាស្ត្រត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគតនេះ។

ការបោះផ្សាយរបាយការណ៍នេះ មានទិសដៅលើកកម្ពស់សមត្ថភាព និងតម្លាភាពនៃវិស័យធនាគារនៅកម្ពុជា។ ទិន្នន័យនៅក្នុងរបាយការណ៍នេះនឹងផ្តល់ជាអត្ថប្រយោជន៍សម្រាប់សាធារណជនក្នុងការប្រើប្រាស់ព័ត៌មានសម្រាប់ជាជំនួយដល់ការសិក្សាស្រាវជ្រាវពីវឌ្ឍនភាពនៃប្រព័ន្ធធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា។

ភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១១

**ជា ចាន់តូ**

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

# មាតិកា


១. ការវិវត្តន៍ម៉ាក្រូសេដ្ឋកិច្ច ........ ១

២. ការអភិវឌ្ឍនៅក្នុងវិស័យហិរញ្ញវត្ថុ ........ ១

២.១. សេចក្តីផ្តើម ........ ១

២.២. លទ្ធភាពប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ ........ ២

២.៣. ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ........ ២

២.៤. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ៣

២.៥. ការអភិវឌ្ឍបទប្បញ្ញត្តិ និងច្បាប់ ........ ៣

៣. ការវិភាគហានិភ័យនៅក្នុងវិស័យធនាគារ ........ ៥

៣.១. ប្រតិបត្តិការនៅក្នុងវិស័យធនាគារ ........ ៥

៣.២. ហានិភ័យឥណទាន ........ ៦

៣.៣. ហានិភ័យសាច់ប្រាក់ងាយស្រួល ........ ៧

៣.៤. ហានិភ័យទីផ្សារ ........ ៨

៣.៥. ហានិភ័យប្រតិបត្តិការ ........ ៩

៣.៦. ដើមទុន និងលទ្ធភាពស្វែងរកប្រាក់ចំណេញ ........ ១០

៣.៧. ប្រតិបត្តិការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ........ ១០

៣.៨. ហានិភ័យ និងភាពផុយស្រួយនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ........ ១១

៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ១៣

៥. ការប្រឈមសំខាន់ៗនៅក្នុងការត្រួតពិនិត្យធនាគារ ........ ១៣

ឧបសម្ព័ន្ធទី១ : ទិន្នន័យគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ឆ្នាំ ២០១០ ........ ១៤

ឧបសម្ព័ន្ធទី២ : អត្រាការប្រាក់ ........ ១៥

ឧបសម្ព័ន្ធទី៣ : ប្រព័ន្ធធនាគារនៅកម្ពុជា ........ ១៧

រាល់ទិន្នន័យដែលបង្ហាញនេះត្រូវបានរៀបចំ និងចងក្រងដោយ

# ធនាគារជាតិនៃកម្ពុជា

**ចំណែកទិន្នន័យ GDP ទទួលបានពីខាងវិទ្យាស្ថានផែនការ និងស្ថិតិ**

# របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ២០១០

## ១. ការវិវត្តន៍ម៉ាក្រូសេដ្ឋកិច្ច

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលមកពីសេដ្ឋកិច្ចកម្ពុជាត្រូវបានបន្ធូរបន្ថយ ។ ទស្សនទានសេដ្ឋកិច្ចបានបង្ហាញពីការកើនឡើងវិញក្នុងឆ្នាំ២០១០ និងសញ្ញាណដ៏ល្អសម្រាប់រយៈពេលខាងមុខ ។ កំណើនផលិតផលក្នុងស្រុកសរុបព្យាករណ៍ដោយរដ្ឋាភិបាលមានចំនួន ៥.៥% បន្ទាប់ពីការធ្លាក់ចុះមកត្រឹម ០.១% ក្នុងឆ្នាំ២០០៩ ។ កំណើននេះចូលរួម ចំណែកដោយកំណើននៅក្នុងវិស័យកសិកម្មមានចំនួន ២៣% កំណើនវិស័យឧស្សាហកម្មចំនួន ៥.៧% និងកំណើន វិស័យសេវាកម្មចំនួន ២.៤% ។ ការព្យាករណ៍សម្រាប់កំណើននៅក្នុងឆ្នាំ២០១១ មានចំនួន ៦.៨% ។

អត្រាអតិផរណាធ្លាក់ចុះមកត្រឹម ៣.១៤% ក្នុងឆ្នាំ២០១០ ពីកម្រិត ៥.៣% ក្នុងឆ្នាំ២០០៩ ដោយសារការថយចុះនៃតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ ។ អត្រាអតិផរណាស្នូលមិនគិតពីតម្លៃទំនិញ និងប្រេងឥន្ធនៈមានកម្រិតត្រឹមតែ ០.៥% ប៉ុណ្ណោះ ។ អត្រាប្តូរប្រាក់ជាមធ្យមសម្រាប់ឆ្នាំ២០១០ ស្ថិតនៅក្នុងកម្រិត ៤.១៩៨ រៀលក្នុងមួយដុល្លារអាមេរិក ធ្លាក់ចុះ ១% ធៀបនឹងឆ្នាំ២០០៩ ។ ការនាំចេញ និងការនាំចូលប្រចាំឆ្នាំកើនឡើង ៩.៥% និង ១១.៧% ពីឆ្នាំ២០០៩ ប៉ុន្តែឱនភាពជញ្ជីងទូទាត់មានកម្រិតខ្ពស់ជាងមុន ។

ការកើនឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាត្រូវបានចូលរួមចំណែកដោយលំហូរចូលនៃទុនបរទេស និងការរីកចំរើននៃវិស័យសេដ្ឋកិច្ចចំបងៗ ដូចជា វិស័យវាយណភ័ណ្ឌ ទេសចរណ៍ សំណង់ និងកសិកម្ម ។ វិនិយោគផ្ទាល់ពីបរទេសកើនឡើងចំនួន ៨.២២% នៅក្នុងឆ្នាំ២០១០ ។ វិស័យវាយណភ័ណ្ឌនាំចេញ និងទេសចរណ៍ កើនឡើងចំនួន ១៥.៣% និង ១៦.៤% ចំណែកវិស័យសំណង់កើនឡើង ១០.១៤% បើធៀបពីឆ្នាំមុន ។

## ២. ការអភិវឌ្ឍនៅក្នុងវិស័យហិរញ្ញវត្ថុ

### ២.១ សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ដែលអនុម័តដោយរាជរដ្ឋាភិបាលបានកំណត់បញ្ហាចំបងៗនៅក្នុងវិស័យហិរញ្ញវត្ថុ និងកំណត់ផែនការសកម្មភាពចំបងៗសម្រាប់ធ្វើការអភិវឌ្ឍ ។ ផែនការអភិវឌ្ឍនេះ ត្រូវធ្វើការកែសម្រួលទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍នេះ អនុវត្តតាមទស្សនៈវិស័យរយៈពេលវែងនៅក្នុងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ប៉ុន្តែត្រូវធ្វើបច្ចុប្បន្នកម្មបន្ថែមទៀត ដើម្បីឲ្យសមស្របទៅនឹងស្ថានភាពនៃឧស្សាហកម្មហិរញ្ញវត្ថុនៅក្នុងប្រទេស និងកំណត់អាទិភាពសម្រាប់ធ្វើការអភិវឌ្ឍ ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ក៏បានបន្ថែមនូវបុរេលក្ខខណ្ឌ និងការពិចារណាអំពីទំនាក់ទំនងលើវិស័យនិមួយៗ ដើម្បីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជារួម ។ ឆ្លងកាត់រយៈពេល ៥ ឆ្នាំកន្លងមកនេះ សមិទ្ធិផលសំខាន់ៗត្រូវបានសម្រេចជាពិសេសនៅក្នុងវិស័យធនាគារ ។

## ២.២ លទ្ធភាពប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ

លទ្ធភាពប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ គឺជាការយកចិត្តទុកដាក់យ៉ាងសំខាន់ពីសំណាក់ធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញ និងផ្តល់ភាពងាយស្រួលដល់ប្រជាជនកម្ពុជាទូទាំងប្រទេសឲ្យមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុ ។ តាមរយៈនេះ ធនាគារជាតិនៃកម្ពុជាបានលើកទឹកចិត្តឲ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុពង្រីកប្រតិបត្តិការរបស់ខ្លួននៅតាមសាខាខេត្ត និងស្រុកនានាទូទាំងប្រទេស ។ ជាងនេះទៀត ការអនុញ្ញាតឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ក៏បានជម្រុញឲ្យមានកំណើនក្នុងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ និងទម្លាប់សន្សំប្រាក់ផងដែរ ដោយប្រជាជននៅតាមតំបន់ជនបទមានលទ្ធភាពដាក់ប្រាក់សន្សំរបស់ខ្លួននៅកន្លែងដែលមានសុវត្ថិភាព ។

ម្យ៉ាងវិញទៀត យន្តការផ្តល់សេវាកម្មហិរញ្ញវត្ថុបច្ចុប្បន្នត្រូវបានច្នៃប្រឌិត និងពង្រីកបន្ថែម ដោយក្នុងនោះ ធនាគារជាតិនៃកម្ពុជាបានផ្តល់លទ្ធភាពឲ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ ដូចជា សេវាផ្ទេរនិងទូទាត់តាមទូរស័ព្ទចល័ត (Mobile Phone Banking) និងសេវាធនាគារតាមប្រព័ន្ធអ៊ីនធឺណែត (Internet Banking) ក្នុងន័យផ្តល់សេវាកម្មរបស់ខ្លួនឲ្យបានកាន់តែទូលំទូលាយ ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ គឺក្នុងគោលបំណងជាសំខាន់ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ និងអាចផ្តល់ដល់អតិថិជនដែលនៅតំបន់ជនបទឆ្ងាយៗក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុទាំងនោះ ។

ទន្ទឹមនឹងនេះ ការប្រើប្រាស់សេវាកម្មថ្មីនេះ ក៏ត្រូវប្រឈមជាមួយឧបសគ្គមួយចំនួនដូចជា ត្រូវមានចំណេះដឹងពីបច្ចេកវិទ្យាថ្មី និងប្រតិបត្តិការហិរញ្ញវត្ថុជាដើម ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តផ្តល់ចំណេះដឹងអំពីវិស័យហិរញ្ញវត្ថុដល់សាធារណៈជន តាមរយៈការបង្ហាញដល់និស្សិតតាមមហាវិទ្យាល័យ និងផ្តល់លទ្ធភាពឲ្យនិស្សិតទាំងនោះធ្វើកម្មសិក្សានៅធនាគារជាតិនៃកម្ពុជា និងការធ្វើសិក្ខាសាលានៅតាមបណ្តាលខេត្តនានា ដើម្បីបង្កើនការយល់ដឹងពីសេវាកម្មហិរញ្ញវត្ថុ ។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តការសហការណ៍ជាមួយដៃគូអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងវិស័យឯកជនជាដើម ក្នុងន័យលើកកម្ពស់ និងពង្រីកសេវាកម្មហិរញ្ញវត្ថុឲ្យមានការប្រើប្រាស់កាន់តែច្រើនពីប្រជាពលរដ្ឋកម្ពុជា ។

## ២.៣ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បានទទួលស្គាល់ពីសារៈសំខាន់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្របមួយក្នុងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុក្នុងនោះរួមមាន រៀបចំប្រព័ន្ធទូទាត់អេឡិចត្រូនិក ការអភិវឌ្ឍទីផ្សារអន្តរធនាគារ ការបង្កើតការិយាល័យព័ត៌មានឥណទាន ពង្រឹងអភិបាលកិច្ច ព្រមទាំងកិច្ចការសំខាន់ផ្សេងៗទៀត ។ ការអភិវឌ្ឍទីផ្សារអន្តរធនាគារ ត្រូវបានរៀបចំឡើងដើម្បីផ្តល់លទ្ធភាពឲ្យគ្រឹះស្ថានធនាគារអាចមានលទ្ធភាពខ្ចីប្រាក់ងាយស្រួលរយៈពេលខ្លីពីគ្នាទៅវិញទៅមក ។ ចំពោះការបង្កើតការិយាល័យចែករំលែកព័ត៌មានឥណទាន ត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រមូលព័ត៌មានឥណទាន និងឲ្យបានដឹងពីប្រវត្តិសងប្រាក់របស់អ្នកខ្ចីឥណទានទាំងនោះ ។

ការបង្កើតការិយាល័យនេះ បានជួយសម្រួលដល់ដំណើរការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារ ព្រោះថា គ្រឹះស្ថានអាចផ្តល់ឥណទានដោយផ្អែកលើប្រវត្តិនៃការសងប្រាក់របស់អតិថិជន ហើយចំពោះអតិថិជនដែលមានប្រវត្តិសងល្អអាចចចារជាមួយគ្រឹះស្ថាន ដើម្បីទទួលបាននូវអត្រាការប្រាក់ទាបជាងមុន ។ ការិយាល័យនេះ នឹងត្រូវបានបង្កើតឡើងនាពេលឆាប់ៗខាងមុខក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានានិរន្តរភាព តម្លាភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃប្រព័ន្ធនេះ ព្រមទាំងការការពារសិទ្ធិរបស់អតិថិជន ។ ដោយឡែក ការពង្រឹងអភិបាលកិច្ចនៅក្នុងគ្រឹះស្ថានធនាគារ ត្រូវបានអនុវត្តជាប្រចាំដោយសារអភិបាលកិច្ចជាក្បាលម៉ាស៊ីននៃដំណើរការអាជីវកម្មរបស់គ្រឹះស្ថានធនាគារ ។ ការអនុវត្តអភិបាលកិច្ចដ៏ល្អ សំដៅដល់ការបែងចែកភារកិច្ចច្បាស់លាស់ និងដាច់ពីគ្នាមានតម្លាភាព ហើយគណៈគ្រប់គ្រង និងនិយោជិតរបស់គ្រឹះស្ថានធនាគារមានគុណវុឌ្ឍិគ្រប់គ្រាន់ និងសមស្រប ។ ធនាគារជាតិនៃកម្ពុជា កំពុងពង្រឹងនូវការអនុវត្តប្រកាស និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងអភិបាលកិច្ច ដើម្បី លើកកម្ពស់អភិបាលកិច្ចនៅក្នុងគ្រឹះស្ថាន ។

## ២.៤ ការបណ្តុះបណ្តាលធនធានមនុស្ស

ធនាគារជាតិនៃកម្ពុជា ពឹងផ្អែកទាំងស្រុងលើមន្ត្រីដែលមានចំណេះដឹង បទពិសោធន៍ និងសុភវិនិច្ឆ័យ ។ ប្រសិទ្ធភាពរបស់ធនាគារកណ្តាល ផ្អែកជាសំខាន់លើជំនឿទុកចិត្តរបស់សាធារណៈជន ហើយប្រការនេះ ស្តែងចេញតាមរយៈគុណវុឌ្ឍរបស់មន្ត្រីត្រួតពិនិត្យ ។ ដើម្បីជំរុញនិងអភិវឌ្ឍធនធានមនុស្ស ជាពិសេសនៅក្នុងផ្នែកត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាធ្វើការពង្រឹងសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលក្នុងប្រទេស និងក្រៅប្រទេស ។ ការបណ្តុះបណ្តាលក្នុងប្រទេសត្រូវបានធ្វើឡើងតាមរយៈការធ្វើការងារដោយផ្ទាល់ និងការចែករំលែកនូវបទពិសោធន៍ដល់គ្នាទៅវិញទៅមករវាងមន្ត្រីធនាគារជាតិនៃកម្ពុជា ចំណែកការបណ្តុះបណ្តាលក្រៅប្រទេសភាគច្រើន មានក្រោម រូបភាពជាសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានាក្នុងតំបន់ ។ ម្យ៉ាងទៀត ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាមាន បំណងឲ្យមន្ត្រីទាំងអស់មានការយល់ដឹងគ្រប់គ្រាន់ពីការអភិវឌ្ឍលើជំនាញដែលពាក់ព័ន្ធក្រោមការគាំទ្រពីស្ថាប័ន មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី មជ្ឈមណ្ឌល SEACEN រតនាគារអាមេរិក និងបណ្តាធនាគារកណ្តាលរបស់ប្រទេសនានាជាដៃគូរ ។

## ២.៥ ការអភិវឌ្ឍបទប្បញ្ញត្តិនិងច្បាប់

ធនាគារជាតិនៃកម្ពុជា ផ្តោតការយកចិត្តទុកដាក់យ៉ាងសំខាន់លើការតាក់តែងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃប្រតិបត្តិការធនាគារ ដោយធ្វើយ៉ាងណាឲ្យតួនាទីជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តទៅប្រកបដោយប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយ ។ នៅក្នុងឆ្នាំ២០១០ នេះ បទប្បញ្ញត្តិមួយចំនួនត្រូវបានកែសម្រួល និងចេញនូវប្រកាសថ្មីៗក្នុងនោះរួមមាន ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពីការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ។ បទប្បញ្ញត្តិទាំងនោះ មិនត្រឹមតែជួយពង្រឹងប្រតិបត្តិការ

របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុលើផ្នែកពាក់ព័ន្ធសំខាន់ៗទាំងនោះទេ ប៉ុន្តែថែមទាំងជួយបំពេញបន្ថែមលើច្បាប់និងបទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីរក្សានូវស្ថិរភាពនិងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ប្រព័ន្ធធនាគារទាំងមូល ។

ប្រកាសស្តីពីការត្រួតពិនិត្យផ្ទៃក្នុង មានគោលបំណងពង្រឹងនូវការត្រួតពិនិត្យរចនាសម្ព័ន្ធដឹកនាំផ្ទៃក្នុងរបស់បណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ជាពិសេស ប្រកាសនេះត្រូវបានចាត់ទុកជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពសម្រាប់ការអនុវត្តជាក់ស្តែងរួមមាន (១) ជួយដល់គណៈគ្រប់គ្រងក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន (២) ជួយដល់ការកំណត់អត្តសញ្ញាណការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យឲ្យបានទាន់ពេលវេលា និង(៣) ជួយដល់ការយល់ដឹងអំពីហានិភ័យ និងការឆ្លើយតបចំពោះវិធានការកែតម្រូវផ្សេងៗ ។

ប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ ត្រូវបានកែសម្រួលឲ្យស្របជាមួយស្តង់ដារអន្តរជាតិ ក្នុងគោលបំណងសំខាន់ ដើម្បីពង្រឹងរចនាសម្ព័ន្ធដើមទុនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យជៀសផុតពីការប្រឈមនឹងភាពប្រែប្រួលជាសក្តានុពល ។ មិនតែប៉ុណ្ណោះ ការកែសម្រួលនេះក៏ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវសមតុល្យនៃធាតុចាំបាច់នីមួយៗ ក្នុងន័យការពារលំហូរយ៉ាងគំហុកនៃធាតុណាមួយ ។

ប្រកាសស្តីពីការអនុវត្តការត្រួតពិនិត្យឈរលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ត្រូវបានដាក់ឲ្យអនុវត្តដើម្បីឆ្លើយតបទៅនឹងគោលការណ៍ស្នូលរបស់ Basel ស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព ។ ការអនុវត្តន៍វិធីសាស្ត្រត្រួតពិនិត្យនេះ អាចឲ្យមន្ត្រីត្រួតពិនិត្យព្យាការណ៍ជាមុននូវសក្តានុពលនៃការវិវត្តន៍ជាអវិជ្ជមាន និងដោះស្រាយទាន់ពេលវេលាតាមរយៈការដាក់ចេញនូវអនុសាសន៍ ដើម្បីអនុវត្តសកម្មភាពកែតម្រូវចាំបាច់ប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាព ។ ម្យ៉ាងទៀត ការអនុវត្តការវាយតម្លៃសំណុំហានិភ័យធនាគារជាតិនៃកម្ពុជា អាចផ្តោតការត្រួតពិនិត្យរបស់ខ្លួនលើបញ្ហាសំខាន់ៗ និងជាពិសេសអាចបែងចែកធនធានសម្រាប់អនុវត្តលើការងារនេះកាន់តែមានប្រសិទ្ធភាព ។

ដូចនេះ តាមរយៈបទពិសោធន៍នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសកល និងការប្រឈមក្នុងការត្រួតពិនិត្យលើវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ធនាគារជាតិនៃកម្ពុជា បានខិតខំផ្តល់នូវក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងដើម្បីជៀសវាងការកេងចំណេញលើបទប្បញ្ញត្តិនៃអ្នកឆ្លៀតឱកាស ។ ធនាគារជាតិនៃកម្ពុជា នឹងបន្តជម្រុញឲ្យបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តពេញលេញនូវច្បាប់ដែលបានដាក់ចេញ ក្នុងន័យរក្សាស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុទាំងមូល ។

# ៣. ការវិភាគហានិភ័យនៅក្នុងវិស័យធនាគារ

## ៣.១ ប្រតិបត្តិការនៅក្នុងវិស័យធនាគារ

នៅចុងឆ្នាំ២០១០ វិស័យធនាគារនៅកម្ពុជា រួមមានធនាគារពាណិជ្ជចំនួន ២៩ និងធនាគារឯកទេសចំនួន ២៦ ។ ទំហំ និងការគ្របដណ្តប់លើប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនីមួយៗមានស្ថានភាពខុសៗគ្នា ។ ផ្អែកលើទ្រព្យសកម្មប្រព័ន្ធធនាគារនៅកម្ពុជា អាចចែកចេញជាធនាគារខ្នាតធំ (មានចំនួន ៤) ធនាគារខ្នាតមធ្យម (មានចំនួន ៧) បុត្រសម្ព័ន្ធធនាគារបរទេស (មានចំនួន ៨) ធនាគារមានភាគទុនិកភាគច្រើនជាបរទេស (មានចំនួន ៦) ធនាគារក្នុងស្រុក (មានចំនួន ៦) និងធនាគារឯកទេស (មានចំនួន ៦) ដែលធនាគារឯកទេសភាគច្រើនជាធនាគារក្នុងស្រុក ។



ប្រតិបត្តិការនៅក្នុងប្រព័ន្ធធនាគារមានការរីកចំរើនខ្លាំងនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ។ ទ្រព្យសកម្មនៅក្នុងប្រព័ន្ធធនាគារមានការកើនឡើង ៥ ដងរហូតដល់ ៥៦% នៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០១០ កើនឡើងពី ២២% ក្នុងឆ្នាំ២០០៥ ។ អន្តរការីធនាគារតាមរយៈការទទួលប្រាក់បញ្ញើ និងការផ្តល់ឥណទានក៏មានការកើនឡើងយ៉ាងខ្លាំងផងដែររហូតដល់ ២៨% និង ៣៧% រៀងគ្នា នៃផលិតផលក្នុងស្រុកសរុបនាបំណាច់ឆ្នាំ២០១០ ដោយអត្រាអន្តរការីយកម្មនេះ មានត្រឹមតែ ៩% និង ១៦% ប៉ុណ្ណោះនៅក្នុងឆ្នាំ២០០៥ ។ សមិទ្ធិផលដែលសម្រេចបាននេះ បានឆ្លងកាត់ដំណាក់ការរីកចំរើនផង និងដំណាក់កាលធ្លាក់ចុះផង ។ នៅក្នុងដំណាក់កាលរីកចំរើនមុនពេលមានវិបត្តិសេដ្ឋកិច្ចសកលកំណើនទាំងឥណទាន និងប្រាក់បញ្ញើនៅក្នុងប្រព័ន្ធធនាគារមានកម្រិតខ្ពស់រហូតដល់ ៧៦% នាឆ្នាំ២០០៧ ។ នៅក្នុងដំណាក់កាលធ្លាក់ចុះ ឥណទានមានកំណើនត្រឹមតែ ៥% នាឆ្នាំ២០០៩ ចំណែកកំណើនប្រាក់បញ្ញើវិញបានធ្លាក់ចុះត្រឹមតែ ៣១% ប៉ុណ្ណោះនាឆ្នាំដដែល ។ នៅក្នុងឆ្នាំ២០១០ កំណើនឥណទានមានការប្រសើរជាងឆ្នាំមុនដែលជាសញ្ញាវិជ្ជមាននៃការងើបឡើងវិញនៃសេដ្ឋកិច្ចនៅកម្ពុជា ។



នៅក្នុងឆ្នាំ២០១០ ចំនួនឥណទាយក និងអ្នកដាក់ប្រាក់បញ្ញើកើនឡើងយ៉ាងគំហុក ទោះបីក្នុងអំឡុងពេលសេដ្ឋកិច្ចមានការធ្លាក់ចុះ ដែលប្រការនេះបង្ហាញពីជំនឿទុកចិត្តយ៉ាងមុតមាំចំពោះវិស័យធនាគារ ។

បើគិតជាតួលេខ ប្រាក់បញ្ញើកើនឡើងប្រមាណ ១ ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះ ៥០% នៃកំណើនប្រមូលផ្តុំទៅក្នុងប្រាក់បញ្ញើសញ្ជ័យ ១០% បន្ថែមលើប្រាក់បញ្ញើមានកាលកំណត់ និង ២០% ប្រមូលផ្តុំក្នុងប្រាក់បញ្ញើចរន្ត ។ ទោះបីយ៉ាងនេះក្តីសមាមាត្រនៃប្រភេទប្រាក់បញ្ញើនីមួយៗនៅក្នុងប្រាក់បញ្ញើសរុបនៅតែនាំមុខ ដោយប្រាក់បញ្ញើមានកាលកំណត់ចំនួន ៤៥% ប្រាក់បញ្ញើសញ្ជ័យចំនួន ៣៦% និងប្រាក់បញ្ញើចរន្តចំនួន ១៩% ។







ប្រការនេះបង្ហាញថា បំរែបំរួលនៃប្រាក់បញ្ញើអតិថិជនមានភាពផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយអត្រាការប្រាក់លើប្រាក់បញ្ញើ ។ដូចគ្នានេះ ប្រភេទឥណទាន ដូចជា ឥណទានវិបារូបន៍ និងឥណទានសម្រាប់ការប្រើប្រាស់ មិនមានបំរែបំរួលខ្លាំង ចំណែកឥណទានសម្រាប់ធ្វើអាជីវកម្មមានកំណើនខ្ពស់ ដែលធ្វើឲ្យសមាមាត្រឥណទានសម្រាប់ធ្វើអាជីវកម្មមានកម្រិតខ្ពស់រហូតដល់ ៦៤% ហើយឥណទានវិបារូបន៍ និងឥណទានសម្រាប់ការប្រើប្រាស់មានកំណើនត្រឹមតែ ១៨% និង ១៧% រៀងគ្នាប៉ុណ្ណោះ ។



## ៣.២ ហានិភ័យឥណទាន

នាបំណាច់ឆ្នាំ២០១០ អត្រាឥណទានមិនដំណើការបានធ្លាក់ចុះដល់ ៣.០៥% ពីកម្រិត ៤.៣៧% នៅក្នុងឆ្នាំ ២០០៩ ចំណែកសំវិធានធនសម្រាប់ឥណទានមិនដំណើការថយចុះពី ៦០%មកត្រឹម ៥៥% នៅក្នុងរយៈពេលដូចគ្នា ។ ឥណទានមិនដំណើរការសុទ្ធបន្ទាប់ពីដកចេញសំវិធានធនមានកម្រិតត្រឹម ១.៣៧% ប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០១០ ។



ឥណទានសម្ព័ន្ធញ្ញាតិកើនឡើងដល់ ១.៧៥% នៃមូលនិធិផ្ទាល់សុទ្ធដែលនេះ គឺស្ថិតនៅក្នុងកម្រិតបទបញ្ញាប្រុងប្រយ័ត្ន ១០% ។ នាបំណាច់ឆ្នាំ២០១០ នេះ

មានធនាគារចំនួន ១៣ បានផ្តល់ឥណទានទៅសម្ព័ន្ធញាតិ ដែលមានកម្រិតខ្ពស់បំផុត ៦.៧៣% និងទាបបំផុតចំនួន ០.០៤% នៃមូលនិធិផ្ទាល់សុទ្ធ ។



ឥណទានហានិភ័យធំសរុប បានកើនឡើងដល់ ៦៩.៨% នៃមូលនិធិផ្ទាល់សុទ្ធ កើនឡើងពី ៥៥.៧% នៅក្នុងឆ្នាំ២០០៩ ។ ឥណទានហានិភ័យធំ បានធ្វើការថ្លឹងហានិភ័យសម្រាប់ឥណទាននីមួយៗ និងឥណទានសរុបស្ថិតនៅក្នុងកម្រិតបទបញ្ញាប្រុងប្រយ័ត្ន ២០% និង ៣០០% រៀងគ្នា ។




ឥណទានតាមវិស័យសេដ្ឋកិច្ចបង្ហាញថាវិស័យជួញដូររាយមានចំណែកខ្ពស់បំផុតចំនួន ១៧.៩% បន្ទាប់មកវិស័យជួញដូរដុំមានចំណែក ១៧.៥% ។ ឥណទានទៅកាន់វិស័យសណ្ឋាគារ និងភោជនីយដ្ឋានកើនឡើងខ្ពស់ជាងឥណទានទៅកាន់វិស័យការមន្តសាល មានចំនួន ៩.៧% និង ៨.៧% ដោយមានវិស័យទេសចរណ៍មានការរីកចំរើន ឡើងវិញឆាប់រហ័ស ។



ឥណទានទៅកាន់វិស័យអចលនទ្រព្យមានចំនួនត្រឹមតែ ១៥.២% នៃឥណទានសរុប ។វិស័យកសិកម្មស្រូបយកបានឥណទានចំនួន ៦.៧% ប៉ុណ្ណោះ ទោះបីវិស័យនេះជាវិស័យមួយដ៏សំខាន់នៅក្នុងខឿនសេដ្ឋកិច្ចក៏ដោយ ។ នាពេលថ្មីៗនេះរាជរដ្ឋាភិបាល បានបន្តភារកិច្ចខិតខំប្រឹងប្រែងក្នុងការជម្រុញឥណទានទៅកាន់វិស័យកសិកម្មតាមរយៈការធានាលើឥណទាន ។ ជាទូទៅការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់ឥណទានស្របតាមការអនុវត្តជាអន្តរជាតិ បានពង្រឹងគុណភាពឥណទាននៅក្នុងគ្រឹះស្ថានបន្ថែមទៀត ដោយសារបទបញ្ញាប្រុងប្រយ័ត្ននេះ បានផ្តល់នូវគោលការណ៍ណែនាំដ៏ល្អក្នុងការកំណត់ឥណទានមិនដំណើរការ ហើយជាមួយគ្នានេះដែរជម្រុញឲ្យគ្រឹះស្ថានធនាគារកាត់បន្ថយហានិភ័យ ។

### ៣.៣ ហានិភ័យសាច់ប្រាក់ងាយស្រួល

អនុបាតសាច់ប្រាក់ងាយស្រួល ជាមធ្យមនៅបំណាច់ឆ្នាំ២០១០ មានកម្រិត ៩០.៦០% ប្រហាក់ប្រហែលនឹងកម្រិតនៅក្នុងឆ្នាំមុន ។ ធនាគារខ្នាតធំមានអនុបាតនេះជាមធ្យមប្រមាណ ៧០% ចំណែកធនាគារទំហំមធ្យម

មានអនុបាតនេះមានប្រមាណ ១១០% ។ ធនាគារខ្នាតតូច ជាពិសេសធនាគារ ដែលទើបបង្កើតថ្មីមានអនុបាតសាច់ប្រាក់ងាយស្រួលខ្ពស់ ដែលបង្ហាញអំពីធនធានទុនបំរុងជាសាច់ប្រាក់ងាយស្រួលដ៏ល្អនៅក្នុងវិស័យធនាគារ ។





## ៣.៤ ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារជាទូទៅ រួមមាន ហានិភ័យអត្រាការប្រាក់ ហានិភ័យអត្រាប្តូរប្រាក់ និងហានិភ័យថ្លៃ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ និងទំនិញជួញដូរមួយចំនួន ។ អវត្តមាននៃទីផ្សារមូលធននិងទីផ្សារទំនិញ ដែលបង្កើតឡើងសម្រាប់ធ្វើការជួញដូរ បានកម្រិតលទ្ធភាពគ្រឹះស្ថានធនាគារវិនិយោគក្នុងទីផ្សារទាំងនោះ ហេតុនេះហានិភ័យថ្លៃដែលជាប់ពាក់ព័ន្ធជាមួយឧបករណ៍ហិរញ្ញវត្ថុ និងទីផ្សារទំនិញសម្រាប់វិស័យធនាគារនៅកម្ពុជាស្ទើរតែអវត្តមានទាំងស្រុង ។ ទោះជាយ៉ាងនេះក្តី ហានិភ័យអត្រាការប្រាក់នៅតែមានតួនាទីចំបងនៅក្នុងអាជីវកម្មធនាគារ ។ អត្រាការប្រាក់រវាងប្រាក់បញ្ញើនិងឥណទានមានគំលាតកើនឡើងនៅបំណាច់ឆ្នាំ២០១០ ។ នៅដើមឆ្នាំ២០០៩ គ្រឹះស្ថានធនាគារមួយចំនួនបានបង្កើនអត្រាការប្រាក់ ដើម្បីទាក់ទាញប្រាក់បញ្ញើបន្ថែមសម្រាប់ទប់ស្កាត់កង្វះខាតសាច់ប្រាក់ងាយស្រួល និងរារាំងការហូរចេញនៃប្រាក់បញ្ញើ ។ ចាប់ពីនោះមកទ្រព្យសកម្មងាយស្រួលមានការកើនឡើងជាលំដាប់ ដោយសារការបញ្ចេញឥណទានមានភាពយឺតយ៉ាវបណ្តាលមកពីការវិនិយោគមិនមានអំណោយផល ។ នាពេលថ្មីៗនេះ តម្រូវការឥណទានមានការកើនឡើង ដែលធ្វើឲ្យថ្លៃដើមហិរញ្ញប្បទានមានការកើនឡើង ។ ទន្ទឹមនឹងនេះប្រាក់បញ្ញើមានកំណើនខ្ពស់ជាងកំណើនឥណទានគួបផ្សំជាមួយលទ្ធភាពអាចទទួលបានហិរញ្ញប្បទានពីក្រៅប្រទេសនូវអត្រាទាបបានជម្រុញឲ្យគ្រឹះស្ថានធនាគារកាត់បន្ថយការប្រាក់លើប្រាក់បញ្ញើ ។ នៅក្នុងរយៈពេលដ៏ខ្លីខាងមុខ ការប្រកួតប្រជែងនឹងអាចជម្រុញឲ្យអត្រាការប្រាក់សម្រាប់ឥណទានធ្លាក់ចុះមកវិញ ចំណែកប្រាក់បញ្ញើនឹងបន្តកើនឡើងរហូតដល់អត្រាការប្រាក់លើប្រាក់បញ្ញើធ្លាក់ចុះបន្ថែមទៀត ។ ចំណែកហានិភ័យអត្រាប្តូរប្រាក់មានឥទ្ធិពលតិចតួចនៅក្នុងអាជីវកម្មធនាគារនៅកម្ពុជា ។ ការកត់ត្រាគណនេយ្យនៅក្នុងគ្រឹះស្ថានធនាគារ ត្រូវបានអនុញ្ញាតឲ្យធ្វើឡើងជារូបិយប័ណ្ណបរទេសជាពិសេសប្រាក់ដុល្លារអាមេរិក ដោយសារទ្រព្យសកម្មនិងទ្រព្យអកម្មរបស់គ្រឹះស្ថានធនាគារភាគច្រើនស្ថិតនៅក្នុងទម្រង់ប្រាក់ដុល្លារអាមេរិក ។ ការជួញដូររូបិយវត្ថុនៅក្នុងគ្រឹះស្ថានធនាគារ មិនទាន់មានលក្ខណៈជា

ជុំកំភូននៅឡើយទេ ។ ស្ថានភាពរូបិយវត្ថុចំហនៅក្នុងតារាងតុល្យការ និងក្រៅតារាងតុល្យការស្ថិតនៅក្នុងកម្រិតបទបញ្ជាប្រុងប្រយ័ត្ន ២០%នៃមូលនិធិផ្ទាល់សុទ្ធ។






## ៣.៥ ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការចាប់ផ្តើមមានសំពាធខ្លាំងក្លាចំពោះប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ ។ កន្លងមកមានកិច្ចខិតខំប្រឹងប្រែងតិចតួចប៉ុណ្ណោះ ក្នុងការរៀបចំបទប្បញ្ញត្តិ និង ការត្រួតពិនិត្យដែលពាក់ព័ន្ធហានិភ័យប្រតិបត្តិការ ។

នាពេលថ្មីៗនេះ មានគោលការណ៍ណែនាំជាច្រើនត្រូវបានដាក់ចេញដើម្បីធានាថា កត្តាដែលជាគន្លឹះនៅក្នុងហានិភ័យប្រតិបត្តិការស្ថិតនៅក្នុងកម្រិត ដែលអាចគ្រប់គ្រងបាន ដូចជាការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពីអភិបាលកិច្ចលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របនិងការត្រួតពិនិត្យផ្ទៃក្នុងជាដើម ។ បទប្បញ្ញត្តិទាំងនេះមានគោលបំណងកាត់បន្ថយហានិភ័យប្រតិបត្តិការដែលបណ្តាលមកពីកត្តាចំបងៗ ដូចជា កត្តានិយោជិត ការរៀបចំដំណើរការនៃការងារ និងប្រព័ន្ធព័ត៌មានវិទ្យាជាដើម ។ ចាប់តាំងពីការដាក់ចេញឲ្យអនុវត្តនូវប្រកាសខាងលើផ្នែកសំខាន់ៗ ទាំងនេះត្រូវបានពង្រឹងបន្ថែមទៀតនៅក្នុងគ្រឹះស្ថានធនាគារដូចជា ការជ្រើសរើសបុគ្គលិកដែលមានជំនាញ និងមានបទពិសោធន៍ខ្ពស់ ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងការបាត់បង់នៅក្នុងប្រតិបត្តិការមានកម្រិតទាប ។

ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារត្រូវបានទទួលរងឥទ្ធិពលពីកត្តាខាងក្រៅដូចជា ស្ថានភាពសេដ្ឋកិច្ច និងអាជីវកម្ម បរិដ្ឋានច្បាប់និងបទប្បញ្ញត្តិ និងកត្តាផ្សេងទៀតរួមទាំងគ្រោះមហន្តរាយផ្សេងៗ ។ បន្ទាប់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងឆ្នាំ២០០៩ ការប្រកួតប្រជែងនៅក្នុងវិស័យធនាគារមានការកើនឡើង ដោយមានចំនួនគ្រឹះស្ថានមានការកើនឡើង ហើយបរិស្ថានអាជីវកម្មមានភាពប្រសើរឡើង ។ ការប្រកួតប្រជែងតាមរយៈថ្លៃផលិតផលសេវាកម្ម និងតំបន់ប្រតិបត្តិការមានសន្ទុះខ្លាំងក្លា ។ បំរែបំរួលអត្រាការប្រាក់មានភាពញឹកញាប់ជាងមុន ហើយផលិតផលធនាគារជាច្រើនប្រភេទ ត្រូវបានផ្តល់ជូនអតិថិជន ។ បណ្តាញសាខារបស់ធនាគារបញ្ជរប្តូរប្រាក់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ បានរីកសាយភាយពាសពេញផ្ទៃប្រទេស ។ ការរៀបចំច្បាប់ និងបទប្បញ្ញត្តិ ត្រូវបានធ្វើឡើង ដើម្បីបង្កើតបរិស្ថានមួយជម្រុញឲ្យមានការរីកចំរើននៅក្នុងវិស័យធនាគារ ប៉ុន្តែប្រកបទៅដោយការប្រុងប្រយ័ត្ន ។ បទបញ្ជាប្រុងប្រយ័ត្ន ដែលបានដាក់ឲ្យអនុវត្តនាពេលថ្មីៗនេះ បានជំរុញឲ្យគ្រឹះស្ថានធនាគារធ្វើការកែសម្រួលរចនាសម្ព័ន្ធ ដើម្បីពង្រឹងប្រតិបត្តិការរបស់ខ្លួន ។

## ៣.៦ ដើមទុន និងលទ្ធភាពស្វែងរកចំណេញ

នៅដំណាច់ឆ្នាំ២០១០ អនុបាតសាធនភាពនៅក្នុងប្រព័ន្ធធនាគារថយចុះបន្តិចមកនៅត្រឹមកម្រិត ៣១,៣៨% ទោះបីជាមូលនិធិផ្ទាល់សុទ្ធកើនឡើង ២៦% ដោយសារការបង្កើនដើមទុន ដើម្បីអនុវត្តនូវកម្រិតដើមទុនអប្បបរមា។ ដើមទុនថ្នាក់ទី១ មានកម្រិតរហូតដល់ ៩៥% នៃមូលនិធិផ្ទាល់សុទ្ធ ដែលបង្ហាញពីមូលដ្ឋានដើមទុនដែលមានស្ថេរភាព ។ មានធនាគារតិចតួចប៉ុណ្ណោះ ដែលមានដើមទុនថ្នាក់ទី២ នៅក្នុងរចនាសម្ព័ន្ធដើមទុន ។



ប៉ុន្តែ រចនាសម្ព័ន្ធនេះ នឹងមានការផ្លាស់ប្តូរបន្ទាប់ពីការដាក់ឲ្យអនុវត្តនូវប្រកាសថ្មី ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ នាពេលដ៏ខ្លីខាងមុខនេះ មូលនិធិផ្ទាល់សុទ្ធនៅក្នុងប្រព័ន្ធធនាគារ ត្រូវបានរំពឹងទុកថា នឹងមានការកើនឡើង ដោយសារប្រាក់ចំណេញប្រចាំឆ្នាំ នឹងរួមបញ្ចូលនៅក្នុងដើមទុនថ្នាក់ទី១ បន្ទាប់ពីការធ្វើសវនកម្មរួច ។

ប្រាក់ចំណេញធៀបទ្រព្យសកម្ម និងធៀបដើមទុនកើនឡើងបន្តិចដល់ ១,៤៤% និង ៦,៦៣% ។ ការកើនឡើងនេះ បណ្តាលមកពីគុណភាពទ្រព្យសកម្មមានភាពប្រសើរឡើង ដែលតម្រូវឲ្យមានចំណាយសំវិធានធនទាបជាងមុន ។ ការកាត់បន្ថយចំណាយប្រតិបត្តិការ និងចំណាយពន្ធធៀបជាមួយទ្រព្យសកម្ម បានជួយឲ្យប្រាក់ចំណេញមានការកើនឡើងផងដែរ ។ ក្នុងចំណោមធនាគារទាំង ៣៥ ធនាគារ ៧ បានទទួលការខាតបង់ក្នុងនោះធនាគារ ៣ ចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំ២០១០ ។ ធនាគារចំនួន ៣ ផ្សេងទៀតមានចំណាយប្រតិបត្តិការខ្ពស់បន្ទាប់ពីធ្វើប្រតិបត្តិការនៅក្នុងឆ្នាំទី១ ដើម្បីពង្រីកចំណែកទីផ្សាររបស់ខ្លួនខណៈពេល ដែលមានធនាគារចំនួន ១ កំពុងស្ថិតក្នុងដំណាក់កាលជម្រះបញ្ជី ។ ជារួមស្ថានភាពដើមទុននៅក្នុងប្រព័ន្ធធនាគារមានភាពរឹងមាំ ដែលអាចស្រូបយកបាននូវការខាតបង់កម្រិតខ្ពស់ ។ ទោះជាយ៉ាងណាក្តី ការកើនឡើងឥណទានមានកម្រិតខ្ពស់ចាំបាច់ត្រូវធ្វើការតាមដានដោយយកចិត្តទុកដាក់ ។



## ៣.៧ ប្រតិបត្តិការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ

ក្នុងកំឡុងពេល ២ ទសវត្សមកនេះ ធនាគារជាតិនៃកម្ពុជា បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ ដើម្បីលើកកំពស់ជីវភាពប្រជាពលរដ្ឋ ជាពិសេសពលរដ្ឋដែលរស់នៅតាមទីជនបទ ។ ក្នុងកំឡុងពេលនេះ វិស័យមីក្រូហិរញ្ញវត្ថុមានការរីកចំរើនយ៉ាងខ្លាំងតួយ៉ាង ដូចជា កំណើនចំនួនគ្រឹះស្ថាន និងចំនួនប្រជាពលរដ្ឋមានលទ្ធភាពទទួលបានសេវាកម្មហិរញ្ញវត្ថុ ។ ទ្រព្យសកម្ម

នៅក្នុងវិស័យនេះ កើនឡើង ១០ ដងពីឆ្នាំ២០០៥ មកដល់ ៥០៦ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១០ ។ ចំនួនឥណទាយកឈានជិតមកដល់ ១លានគណនី នៅដំណាច់ឆ្នាំ២០១០ ។



មុនពេលធ្វើកំណែទម្រង់នៅក្នុងឆ្នាំ២០០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនត្រូវបានអនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីអតិថិជនក្រៅពីប្រាក់បញ្ញើកាតព្វកិច្ចនោះឡើយ ។ បន្ទាប់ពីការដាក់ឲ្យអនុវត្តនូវប្រកាសស្តីពីគ្រឹះស្ថានមីក្រូហិញ្ញវត្ថុទទួលប្រាក់បញ្ញើ មានការកើនឡើងពី ១០លានដុល្លារអាមេរិក មកដល់ ៤០ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១០ ។ ទោះជាយ៉ាងនេះក្តី ការគៀងគរប្រាក់បញ្ញើនេះមានភាពមិនគ្រប់គ្រាន់ សម្រាប់ទ្រទ្រង់កំណើនឥណទាននោះទេ ។ គ្រឹះស្ថានបង្កើនខ្ទង់បំណុលរបស់ខ្លួនដើម្បីផ្គត់ផ្គង់កំណើនឥណទាន ។ ការគ្រប់គ្រងគ្រឹះស្ថានប្រកបដោយអភិបាលកិច្ចល្អ ជាពិសេស តម្លាភាពខ្ពស់នៅក្នុងប្រតិបត្តិការអាចជួយឲ្យវិស័យនេះ អាចឈោងចាប់ប្រភពមូលនិធិពីបរទេសបានយ៉ាងងាយស្រួល ។





## ៣.៨ ហានិភ័យ និងភាពផុយស្រួយនៅក្នុង វិស័យមីក្រូហិរញ្ញវត្ថុ

ប្រតិបត្តិការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានជួបប្រទះនូវហានិភ័យជាច្រើនផងដែរ ដូចជា ហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ។ ហានិភ័យឥណទាន នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ មិនមានការព្រួយបារម្ភណ៍ជាដុំកំភួននោះទេ ដោយសារឥណទានមិនដំណើរការជាទូទៅមានកម្រិតទាប ។ មុនពេលមានវិបត្តិសេដ្ឋកិច្ចសកល អនុបាតឥណទានមិនដំណើរការមានកម្រិតទាបជាង ១% នៃសំពៀតឥណទានសរុប ។ អនុបាតនេះ កើនឡើងដល់កម្រិតខ្ពស់បំផុត ២,៨០% ក្នុងឆ្នាំ២០០៩ ហើយធ្លាក់ចុះមកត្រឹម ១,២០% នៅបំណាច់ឆ្នាំ២០១០។



ហានិភ័យសាច់ប្រាក់ងាយស្រួលបណ្តាលមកពីអ្នកដាក់ប្រាក់បញ្ញើនីមួយៗមានកម្រិតទាបផងដែរ ដោយសារការបើកទូលាយឲ្យមានការទទួលប្រាក់បញ្ញើជាសាធារណៈត្រូវបានអនុញ្ញាតនៅក្នុងឆ្នាំ២០០៩ប៉ុណ្ណោះ ហើយមូលដ្ឋានប្រាក់បញ្ញើនេះមានកម្រិតទាបធៀបជាមួយទ្រព្យសកម្មងាយស្រួលរបស់គ្រឹះស្ថាន ។



កម្ចីរបស់គ្រឹះស្ថាន ដែលជាទូទៅមានរយៈពេលខ្លី និងវែងត្រូវបានកំណត់ឥណប្រតិទានឲ្យមានភាពស៊ីសង្វាក់ជាមួយទ្រព្យសកម្មងាយស្រួល ។



គម្លាតអត្រាការប្រាក់រវាងប្រាក់បញ្ញើ និងឥណទានមានកម្រិតខ្ពស់ ទោះបីជាការប្រកួតប្រជែងមានការកើនឡើងក៏ដោយ ។ ប្រការនេះ បានបង្ហាញផងដែរអំពីមូលហេតុ ដែលវិស័យមីក្រូហិរញ្ញវត្ថុអាចទាក់ទាញមូលនិធិពីក្រៅប្រទេស ដើម្បីទ្រទ្រង់កំណើនឥណទាន។ ស្ថានភាពរូបិយវត្ថុចំហរបានបង្ហាញនូវបញ្ហា ដែលត្រូវចាប់អារម្មណ៍ ដោយសារឥណទានជារូបិយវត្ថុមានការកើនឡើងខណៈពេល ដែលប្រភពមូលនិធិ ដែលទទួលបានភាគច្រើនជារូបិយប័ណ្ណ ជាពិសេសប្រាក់ដុល្លារអាមេរិក ។ ហានិភ័យប្រតិបត្តិការមានកម្រិតបង្គួរ ដោយសារតំបន់ប្រតិបត្តិការរបស់គ្រឹះស្ថានស្ថិតនៅពាសពេញផ្ទៃប្រទេស ដែលអាចដឹងពីផលប៉ះពាល់បណ្តាលមកពីអាកាសធាតុ និងគ្រោះធម្មជាតិផ្សេងៗ ។ ស្ថានភាពដើមទុនរបស់វិស័យមីក្រូហិរញ្ញវត្ថុមានភាពរឹងមាំ ដោយសារអនុបាតសាធនភាពជាមធ្យមមានកម្រិត ២២% ។ លទ្ធភាពស្វែងរកចំណេញ នៅក្នុងវិស័យនេះមានការកើនឡើងបន្តិចជាងពីឆ្នាំមុន ដោយសារស្ថានភាពសេដ្ឋកិច្ចនៅក្នុងប្រទេសបានងើបឡើងវិញ ។

## ៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាបានទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការជាអន្តរជាតិជាពិសេសជាមួយអាជ្ញាធរត្រួតពិនិត្យនៅក្នុងតំបន់ជាគន្លឹះក្នុងការពង្រឹងសមត្ថភាពត្រួតពិនិត្យ ។ កិច្ចសហប្រតិបត្តិការនេះអាចជួយឲ្យធនាគារជាតិនៃកម្ពុជាចែករំលែកបទពិសោធន៍ជាមួយអាជ្ញាធរត្រួតពិនិត្យប្រទេសផ្សេងៗទៀត និងអាចជួយកាត់បន្ថយហានិភ័យដែលកើតឡើងនៅក្រៅប្រទេស ។ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សារណៈយោគយល់ជាមួយធនាគារកណ្តាលវៀតណាម និងធនាគារកណ្តាលម៉ាឡេស៊ី ស្តីពីការចែករំលែកព័ត៌មាន និងកិច្ចសហប្រតិបត្តិការក្នុងការត្រួតពិនិត្យ ។ ទម្រង់អនុស្សារណៈយោគយល់នេះកំពុងត្រូវបានរៀបចំជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់ផងដែរ ។

## ៥. ការប្រឈមសំខាន់ៗនៅក្នុងការត្រួតពិនិត្យធនាគារ

ទោះបីជាកិច្ចខិតខំប្រឹងប្រែងចម្បងៗត្រូវបានសម្រេចនៅក្នុងកំឡុងពេលជាងមួយទសវត្ស បន្ទាប់ពីការធ្វើកំណែទម្រង់វិស័យធនាគារនៅក្នុងឆ្នាំ២០០០ នៅមានបញ្ហាប្រឈមជាច្រើនទៀតដែលត្រូវអនុវត្ត ដើម្បីពង្រឹងស្ថេរភាព និងភាពរឹងមាំ និងអភិវឌ្ឍវិស័យធនាគារ ។ ផ្នែកអាទិភាព ដើម្បីធ្វើការពង្រឹងបន្ថែមទៀតស្ថិតនៅលើកំណែទម្រង់ក្របខណ្ឌច្បាប់និងគតិយុត្តិ ។ ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនៅក្នុងវិស័យធនាគារ ត្រូវធ្វើបច្ចុប្បន្នកម្មឲ្យមានភាពសមស្របទៅនឹងស្ថានភាពនាពេលបច្ចុប្បន្ន និងដើម្បីអនុលោមទៅនឹងគោលការណ៍ណែនាំសំរាប់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ។ ក្របខណ្ឌត្រួតពិនិត្យដែលមានកន្លងមកមិនបាន លើកឡើងអំពីបញ្ហាសំខាន់ៗមួយចំនួនដូចជា ការប្រុងប្រយ័ត្នបញ្ចូលនិងទិញការកាន់កាប់ ដែលអាចអនុវត្តបានការត្រួតពិនិត្យប្រុងប្រយ័ត្នបញ្ចូលគ្នា ការត្រួតពិនិត្យឆ្លងដែន សកម្មភាពកែតម្រូវជាបន្ទាន់ និងវិធានការដោះស្រាយគ្រឹះស្ថានដែលមានបញ្ហាទេ ។

ធនាគារជាតិនៃកម្ពុជា កំពុងធ្វើដំណើរឆ្ពោះទៅរកការត្រួតពិនិត្យផ្អែកលើហានិភ័យពីក្របខណ្ឌត្រួតពិនិត្យផ្អែកលើមូលដ្ឋានបទប្បញ្ញត្តិ ។ ប៉ុន្តែនៅក្នុងកំឡុងពេលផ្លាស់ប្តូរនេះ បទប្បញ្ញត្តិនិងគោលការណ៍ណែនាំសំរាប់ការត្រួតពិនិត្យផ្អែកលើហានិភ័យកំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំនិងអភិវឌ្ឍន៍ ហើយស្ថានភាព និងប្រវត្តិរបស់គ្រឹះស្ថានមិនទាន់មានគ្រប់គ្រាន់នៅឡើយ ។ ការដាក់ឲ្យអនុវត្តនូវវិធានការកែតម្រូវឲ្យមានភាពស៊ីសង្វាក់គ្នាសំរាប់គ្រឹះស្ថាននីមួយៗមានភាពស្មុគស្មាញខ្លាំង ។ ដូចនេះ ការសម្របសម្រួលនៅក្នុងដំណាក់កាលផ្លាស់ប្តូរនេះ ជាបញ្ហាប្រឈមដ៏ចម្បង ។

បញ្ហាពាក់ព័ន្ធការត្រួតពិនិត្យប្រុងប្រយ័ត្នបញ្ចូលគ្នា ក៏ជាឧបសគ្គក្នុងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពផងដែរ ។ ក្របខណ្ឌត្រួតពិនិត្យចំពោះពហុក្រុមហ៊ុនហិរញ្ញវត្ថុកំពុងស្ថិតនៅក្នុងដំណាក់កាលរៀបចំ ដើម្បីជម្រុញឲ្យដំណើរការត្រួតពិនិត្យអាចធ្វើឡើងចំពោះក្រុមសម្ព័ន្ធទាំងមូល ។ កត្តាទាំងនេះ ជាបញ្ហាប្រឈមសំរាប់អាជ្ញាធរត្រួតពិនិត្យដោយសារកង្វះខាតបទពិសោធន៍ និងជំនាញ ដូចនេះ ចាំបាច់ត្រូវធ្វើការបំពេញបន្ថែមឲ្យបានឆាប់រហ័ស ។ កង្វះខាតប្រវត្តិហានិភ័យនៃគ្រឹះស្ថាននីមួយៗនៅក្នុងពហុក្រុមហ៊ុនហិរញ្ញវត្ថុ ក៏បានកម្រិតលទ្ធភាពរបស់អាជ្ញាធរត្រួតពិនិត្យក្នុងការវាយតម្លៃហានិភ័យឲ្យបានសមស្រប ។ ដូចនេះ កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិនៅក្នុងវិស័យហិរញ្ញវត្ថុទាំងអស់ចាំបាច់ត្រូវធ្វើឡើង ។

## ឧបសម្ព័ន្ធទី ១

## ទិន្នន័យរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

## ឆ្នាំ ២០១០

(សូមមើលឧបសម្ព័ន្ធទី ១ នៅផ្នែកភាសាអង់គ្លេស)

# ឧបសម្ព័ន្ធ២

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០10) (អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | | ឥណទានជាដុល្លារ | | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | 11.25% | 11.25% | 11.25% | 11.25% | | 11.25% | 11.25% | 11.25% | 11.25% |
| 2 | ធនាគារកាណាឌីយ៉ា ចំកាត់ | | 24.00% | 24.00% | 24.00% | 24.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 3 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | | | | | | | 24.68% | 24.68% | 24.68% | 24.68% | | | | | |
| 4 | ធនាគារមេយប៊ែង | | | | | | | | | | 12.00% | | | | | |
| 5 | ធនាគារក្រុងថៃមហាជន ចំកាត់ | | | | | | | | | | 13.00% | | | | | 10.00% |
| 6 | ធនាគារ វឌ្ឍនៈ | | | | | | | | 11.00% | 10.00% | 12.77% | | | | | |
| 7 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 8 | ធនាគារសាជីវកម្មសឹង្ហបូរី ចំកាត់ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 9 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 10 | ធនាគារមេគង្គកម្ពុជា | | | | | | | 14.40% | 14.40% | 14.40% | 14.40% | | | | | |
| 11 | ធនាគារសហពាណិជ្ជ ក.អ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 12 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | | | | | | | | | | 16.00% | | | | | |
| 13 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | | | | | | | 14.00% | 15.00% | 16.00% | 18.00% | | | | | |
| 14 | ធនាគារពាណិជ្ជកម្មទី១ | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 15 | ធនាគារអេស៊ីលីដា | | | | | 24.00% | | | | | 18.00% | | | | | 24.00% |
| 16 | ធនាគារ អេ អ៊ិន ហ្សេត រូយ៉ាល់ កម្ពុជា | | | | | | | | | | 9.71% | | | | | |
| 17 | ធនាគារខេមខូ លីមីតធីត | | | | | | | | | | 13.00% | | | | | |
| 18 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | | | | | | | | | | 10.00% | | | | | 17.49% |
| 19 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 20 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | | | | | | | 15.50% | 15.50% | 15.50% | 15.50% | | | | | |
| 21 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | | | 15.00% | | | | | |
| 22 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | | | | | 18.00% | | | | | |
| 23 | ធនាគារ អូ អេស ខេ ឥណ្ឌូនេស៊ី | | | | | 14.00% | | | | | 14.00% | | | | | |
| 24 | ធនាគារ អង្គរ កាពីតាល | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| 25 | ធនាគារសាខម | | 11.00% | 11.00% | 11.00% | 11.00% | | 11.00% | 11.00% | 11.00% | 11.00% | | | | | |
| 26 | ធនាគារឥណ្ឌា សាខាភ្នំពេញ | | | | | | | | | | 13.00% | | | | | |
| 27 | ធនាគារហ្វូង ឌីប៊ីអេស | | | | | | | | | | 12.00% | | | | | |
| 28 | ធនាគារ អាហ្គ្រីប៊ែង សាខាកម្ពុជា | | 16.80% | 16.80% | 16.80% | 16.80% | | 16.20% | 16.20% | 16.20% | 16.20% | | | | | |
| 29 | ធនាគារ ស៊ីអាយអិមប៊ី | | | | | | | | | | | | | | | |
| 30 | ធនាគារឯកទេស អានកូ | | | | | | | | | | 17.66% | | | | | |
| 31 | ធនាគារឯកទេសប៊េស | | | | | | | | | | 17.04% | | | | | |
| 32 | ធនាគារឯកទេស ខេមបូឌាន ឌីវេឡុបមេន | | | | | | | | | | | | | | | |
| 33 | ធនាគារឯកទេសវិនិយោគទីមួយ | | | | | | | | 18.00% | 18.00% | 18.00% | | | | | |
| 34 | ធនាគារឯកទេស ភី អេច អេស អឹម អ៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 35 | ធនាគារអភិវឌ្ឍន៍ជនបទ | | | | | 15.00% | | | | | 12.00% | | | | | |
| **មធ្យមក្រោយពេលថ្លឹង** | | | **21.57%** | **21.57%** | **21.57%** | **22.49%** | | **19.48%** | **18.95%** | **18.96%** | **17.15%** | | **11.25%** | **11.25%** | **11.25%** | **22.15%** |
| **មធ្យម** | | | **17.45%** | **17.45%** | **17.45%** | **17.54%** | | **16.25%** | **15.94%** | **15.94%** | **15.34%** | | **11.25%** | **11.25%** | **11.25%** | **15.69%** |

# ឧបសម្ព័ន្ធ២

## អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០10) (អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារកម្ពុជាពាណិជ្ជ ចំកាត់ | 0.10% | | 1.00% | | | 0.10% | | 1.00% | 1.00% | 1.00% | 0.10% | | 1.00% | | |
| 2 | ធនាគារកាណាឌីយ៉ា ចំកាត់ | 2.00% | | 5.00% | 6.00% | 7.00% | 0.75% | 2.25% | 2.75% | 3.75% | 5.00% | | | | | |
| 3 | ធនាគារកម្ពុជាសាធារណៈ ចំកាត់ | 0.50% | | | | | 0.50% | 1.75% | 2.50% | 3.50% | 4.25% | 0.50% | | | | |
| 4 | ធនាគារមេយប៉ែង | | | | | | 1.00% | 1.50% | 2.25% | 2.75% | 3.75% | | | | | |
| 5 | ធនាគារក្រុងថៃមហាជន ចំកាត់ | | | | | | 0.10% | | 0.50% | 0.75% | 1.00% | | | | | |
| 6 | ធនាគារ វឌ្ឍនៈ | | | | | | 0.50% | 1.50% | 2.00% | 3.00% | 3.50% | | | | | |
| 7 | ធនាគារកម្ពុជាអាស៊ី ចំកាត់ | | | | | | 2.00% | 3.00% | 4.00% | 5.00% | 6.00% | | | | | |
| 8 | ធនាគារសាជីវកម្មសឹង្ហបូរី ចំកាត់ | | | | | | 0.50% | | 2.50% | 3.00% | 4.00% | | | | | |
| 9 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.50% | | 4.50% | 5.50% | 6.50% | 0.75% | 1.00% | 3.00% | 4.00% | 5.00% | | | | | |
| 10 | ធនាគារមេគង្គកម្ពុជា | 3.50% | | | | | 2.00% | 2.25% | 2.75% | 3.25% | 3.50% | 2.00% | | | | |
| 11 | ធនាគារសហពាណិជ្ជ ក.អ | | | | | | 1.00% | 2.50% | 3.50% | 4.50% | 5.50% | | | | | |
| 12 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | 3.00% | 2.00% | 3.00% | 4.00% | 5.00% | 3.00% | 2.00% | 3.00% | 4.00% | 5.00% | | | | | |
| 13 | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | 1.00% | | | | | 1.00% | 3.50% | 4.50% | 5.50% | 6.50% | | | | | |
| 14 | ធនាគារពាណិជ្ជកម្មទី១ | | | | | | 0.40% | 1.25% | 1.35% | 1.45% | 1.55% | | | | | |
| 15 | ធនាគារអេស៊ីលីដា | 1.25% | 3.00% | 5.00% | 6.00% | 7.00% | 0.50% | 1.50% | 2.50% | 3.50% | 4.75% | 0.15% | 0.25% | 1.25% | 2.25% | 3.25% |
| 16 | ធនាគារ អេ អ៊ិន ហ្សេត រូយ៉ាល់ កម្ពុជា | 0.50% | 3.25% | 3.50% | 4.00% | 5.50% | 0.25% | 2.00% | 2.50% | 2.90% | 3.35% | 0.15% | 0.35% | 0.75% | 0.90% | 1.05% |
| 17 | ធនាគារខេមខូ លីមីតធីត | | | | | | 1.00% | 3.50% | 4.00% | 5.00% | 6.00% | | | | | |
| 18 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | 2.00% | 3.55% | 4.60% | 5.55% | 6.50% | 2.00% | 2.25% | 3.25% | 4.25% | 5.50% | | | | | |
| 19 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | 0.25% | 1.25% | 1.25% | 1.50% | 1.75% | | | | | |
| 20 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 0.70% | 1.70% | 2.50% | 3.20% | 3.60% | 0.50% | 1.20% | 2.00% | 2.70% | 3.10% | | | | | |
| 21 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.00% | 3.00% | 4.00% | 5.00% | 6.00% | 0.75% | 1.50% | 2.50% | 3.00% | 3.50% | | | | | |
| 22 | ធនាគារភ្នំពេញពាណិជ្ជ | | | | | | 1.20% | 3.70% | 4.20% | 5.20% | 6.20% | | | | | |
| 23 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 2.00% | 3.00% | 3.50% | 4.50% | 5.75% | | | | | |
| 24 | ធនាគារ អង្គរ កាពីតាល | | | | | | | 1.50% | 3.50% | 4.50% | 7.00% | | | | | |
| 25 | ធនាគារសាខម | 1.00% | 3.50% | 4.50% | 5.50% | 6.50% | 0.50% | 2.50% | 4.00% | 4.50% | 5.50% | | | | | |
| 26 | ធនាគារឥណ្ឌា សាខាភ្នំពេញ | | | | | | 0.75% | 1.00% | 2.25% | 3.00% | 4.00% | | | | | |
| 27 | ធនាគារហ្វង ឌីប៊ីអេស | | | | | | 1.00% | 1.75% | 2.25% | 2.75% | 3.25% | | | | | |
| 28 | ធនាគារ អាហ្គ្រីប៉ែង សាខាកម្ពុជា | 1.75% | 3.00% | 4.00% | 4.50% | 5.25% | 1.25% | 2.00% | 3.00% | 3.60% | 4.85% | | | | | |
| 29 | ធនាគារ ស៊ីអាយអិមប៊ី | | | | | | 0.50% | 2.25% | 2.50% | 3.50% | 4.25% | | | | | |
| 30 | ធនាគារឯកទេស អានកូ | | | | | | | | | | | | | | | |
| 31 | ធនាគារឯកទេសប៉េស | | | | | | | | | | | | | | | |
| 32 | ធនាគារឯកទេស ខេមបូឌាន ឌីវេឡុបមេន | | | | | | | | | | | | | | | |
| 33 | ធនាគារឯកទេសវិនិយោគទីមួយ | | | | | | | | | | | | | | | |
| 34 | ធនាគារឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | | | | | | | | | |
| 35 | ធនាគារអភិវឌ្ឍន៍ជនបទ | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.00% | 3.00% | 3.50% | 4.00% | 5.00% | | | | | |
| **មធ្យមភាគក្រោយការថ្លឹង** | | **1.18%** | **3.09%** | **4.50%** | **5.49%** | **6.58%** | **0.66%** | **1.86%** | **2.64%** | **3.50%** | **4.44%** | **0.28%** | **0.29%** | **1.06%** | **1.76%** | **2.45%** |
| **មធ្យមភាគ** | | **1.43%** | **3.00%** | **3.82%** | **4.94%** | **5.90%** | **0.93%** | **2.09%** | **2.74%** | **3.46%** | **4.31%** | **0.58%** | **0.30%** | **1.00%** | **1.58%** | **2.15%** |

## ឧបសម្ព័ន្ធទី៣ ៖ ប្រព័ន្ធធនាគារកម្ពុជា

ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១០

### ធនាគារជាតិ នៃកម្ពុជា

#### ៣០ ធនាគារពាណិជ្ជ

**៧ សាខាធនាគារបរទេស**

១-ធនាគារ ពាណិជ្ជកម្មទីមួយ
២-ធនាគារ ក្រុងថៃ
៣-ធនាគារ មេយបែង
៤-ធនាគារ សាខម
៥-ធនាគារ ឥណ្ឌា សាខាភ្នំពេញ
៦-ធនាគារវិនិយោគ និងអភិវឌ្ឍន៍វៀតណាម (អាហ្គ្រីបែង) សាខាកម្ពុជា
៧-ធនាគារ ចិន សាខាភ្នំពេញ

**២៣ បង្កើតឡើងតាមច្បាប់ក្នុងស្រុក**

១-ធនាគារពាណិជ្ជកម្មក្រៅប្រទេស
២-ធនាគារ វឌ្ឍនៈអាស៊ី
៣-ធនាគារ កម្ពុជាអាស៊ី
៤-ធនាគារ កាណាឌីយ៉ា
៥-ធនាគារ កម្ពុជាពាណិជ្ជ
៦-ធនាគារ កម្ពុជាមេគង្គ
៧-ធនាគារ កម្ពុជាសាធារណៈ
៨-សាជីវកម្ម ធនាគារ សិង្ហបុរី
៩-ធនាគារ សហពាណិជ្ជ
១០-ធនាគារ វឌ្ឍនៈ
១១-ធនាគារ អេស៊ីលីដា
១២-ធនាគារ អេអិនហ្សេតរ៉ូយ៉ាល់
១៣-ធនាគារខេមខូ
១៤-ធនាគារ ស៊ិនហាន ខ្មែរ
១៥-ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា
១៦-ម៉ារ៉ូហាន់ ធនាគារ ជប៉ុន
១៧-ធនាគារគូកមីន
១៨-ធនាគារប៊ូយុងខ្មែរ
១៩-ធនាគារភ្នំពេញពាណិជ្ជ
២០-ធនាគារ អូ អេស ខេ ឥណ្ឌូនៃណា
២១-ធនាគារ អង្គរកាពីតាល់
២២-ធនាគារ ហ្វុង ឌី ប៊ី អេស ពាណិជ្ជ
២៣- ធនាគារ ស៊ីអាចអឹមប៊ី

#### ៦ ធនាគារឯកទេស

**១ ធនាគាររដ្ឋ**

-ធនាគារ អភិវឌ្ឍន៍ជនបទ

**៥ ធនាគារឯកជន**

១-ធនាគារ ឯកទេស P.H.S.M.E
២-ធនាគារឯកទេសវិនិយោគទីមួយ
៣-ធនាគារ ឯកទេសអានកូ
៤-ធនាគារ ឯកទេសខេមបូខាន ឌីវឡុបមេន
៥-ធនាគារឯកទេស ប៊េស

#### ២ ការិយាល័យតំណាង

១- ស្តង់ដារឆាទីរ៉េត
២- ធនាគារកសិកម្មនិងអភិវឌ្ឍន៍នៃវៀតណាម

#### គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**•២៥ មានអាជ្ញាប័ណ្ណ**

១- អម្រឹត
២-ហត្ថាកសិករ
៣- ធនាគារភូមិកម្ពុជា
៤- សិលានិធិ
៥- ក្រុមហ៊ុនស្ថាបនាសហគ្រិនកម្ពុជា
៦- ក្រុមហ៊ុនអង្គរមីក្រូហិរញ្ញវត្ថុ
៧- វីសុនហ្វាន់(ខេមបូឌា)
៨- ក្រុមហ៊ុនក្រេឌីត Co., Ltd.
៩- ប្រាសាក់ ម៉ាយក្រូហ្វាយនែន
១០- សមាគមមូលនិធិសហភាពអភិ.កសិករ
១១- ក្រុមហ៊ុនអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា
១២- ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ
១៣-ឥណទានពលរដ្ឋរុងរឿង
១៤- ហ៊ឺស ហ្វាយនែន
១៥- ហ្វាមើរ ហ្វាយនែន
១៦- ឥណទានអភិវឌ្ឍន៍ប្រជាជន
១៧- ហ្វ្រិន សេនត្រស ម៉ាយក្រូហ្វាយនែន
១៨- សាមិក
១៩- វ៉ាយ ស៊ី ភី
២០-ខេម ខាប់ពីថល
២១-សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ
២២-ខេមា ២៤-អង្គរអេស៊ី អ៊ីស្តារក្រេឌីត
២៥-ខេមរៈ ២៥-ប្រាយម៍ អិមអេហ្វ

**អង្គការក្រៅរដ្ឋាភិបាល**

• ២៨ ចុះបញ្ជី *
• មិនចុះបញ្ជីមានប្រហែល៦០ទៀត

#### ២១សាខាធនាគារជាតិនៅតាមខេត្ត

១-ក្រុងភ្នំពេញ
២-កំពង់ចាម
៣-ក្រុងព្រះសីហនុ
៤-សៀមរាប
៥-បាត់ដំបង
៦-ស្វាយរៀង
៧-កំពត
៨-កណ្តាល
៩-កំពង់ធំ
១០-ពោធិសាត់
១១-កំពង់ស្ពឺ
១២-កោះកុង
១៣-រតនៈគីរី
១៤-មណ្ឌលគីរី
១៥-បន្ទាយមានជ័យ
១៦-ព្រៃវែង
១៧-តាកែវ
១៨-កំពង់ឆ្នាំង
១៩-ព្រះវិហារ
២០-ក្រចេះ
២១-ស្ទឹងត្រែង

#### អាជីវកម្មប្តូរប្រាក់

ភ្នំពេញ ៖
-អាជ្ញាប័ណ្ណ ៩
-លិខិតអនុញ្ញាត ២៦
ខេត្ត ៖
-លិខិតអនុញ្ញាត ៩៤៨

• បើកជាផ្លូវការ

# *អង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីចំនួន ២៨

| | | | |
|---|---|---|---|
| 1 | សមាគមអភិវឌ្ឍន៍កសិកម្ម និងទេសចរណ៍ | 15 | សមាគមអភិវឌ្ឍន៍សណ្តែកសៀងតាអុង |
| 2 | សមាគមជួយកសិករ | 16 | អង្គការ អភិវឌ្ឍន៍របរចិញ្ចឹមជីវិតកសិករ |
| 3 | សមាគមផ្តើមគំនិតពាណិជ្ជកម្ម | 17 | អង្គការអភិវឌ្ឍន៍ជនបទខ្មែរ |
| 4 | សមាគមសំណាងអភិវឌ្ឍន៍ជនបទ | 18 | សមាគមសុខមាលភាពស្ត្រីខេត្តក្រចេះ |
| 5 | ស៊ី អាយ ស៊ី អេម កម្ពុជា | 19 | អង្គការលូថេរ៉ាន បំរើពិភពលោក |
| 6 | អង្គការតេណទានលុបបំបាត់ភាពក្រីក្រកម្ពុជា | 20 | គំរោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ |
| 7 | អង្គការបណ្តាញសេដ្ឋកិច្ចកម្ពុជា | 21 | អង្គការក្រុមការងារសេដ្ឋកិច្ចថ្មី |
| 8 | អង្គការសង្គហអភិវឌ្ឍន៍កម្ពុជា | 22 | សមាគមអភិវឌ្ឍន៍តំបន់ពាយ័ព្យ |
| 9 | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅកម្ពុជា | 23 | វិទ្យាស្ថានសន្តិភាព និងអភិវឌ្ឍន៍ |
| 10 | សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា | 24 | អង្គការ សប្បុរស |
| 11 | អង្គការ ច័ន្ទ សុខសាន្ត | 25 | អង្គការអភិវឌ្ឍន៍សង្គមជនបទ |
| 12 | អង្គការ ចំរើន មីក្រូហិរញ្ញវត្ថុ | 26 | អង្គការពន្លឺព្រះអាទិត្យរះ |
| 13 | អង្គការទ្រទ្រង់សហគមន៍បង្កើនអភិវឌ្ឍន៍ | 27 | សមាគមន៍ អភិវឌ្ឍន៍ភូមិ |
| 14 | សមាគមជាតិទ្រទ្រង់កសិផល | 28 | ស៊ីខេអ៊ឹមអេហ្វជី ខេមបូឌា |